ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ២៥៥
ថ្ងៃ: សុក្រ ទី១៤ ខែ ធ្នូ ឆ្នាំ២០១៨
ម៉ោង: ១៥:៤០ នាទី

# ព្រះរាជក្រម

## យើង

នស/រកម/១២១៨/ ០១៧

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៩

# ជំពូកទី១
## ថវិកាថ្នាក់ជាតិ

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ឱ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិនូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឱ្យសម្រេចនូវឧបត្ថម្ភធនវិនិយោគនិងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "**ក១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន២៥ ៣៦០ ០២៨លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត........................................................ ១៩ ៥៩៣ ១១១លានរៀល
- ចំណូលមូលធន....................................................៥ ៧៦៦ ៩១៧លានរៀល

  \+ ចំណូលមូលធនក្នុងប្រទេស................................ ១៩៣ ១៤៩លានរៀល

  \+ ចំណូលមូលធនក្រៅប្រទេស.............................៥ ៥៧៣ ៧៦៨លានរៀល

  - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ
    ..............................................................២៥០ ០០០លានរៀល
  - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស
    ........................................................៥ ៣២៣ ៧៦៨លានរៀល។

**មាត្រា២ .-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានកំណត់ស្មើនឹង២៥ ៧៦៥ ០២៨លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត.................................................... ១៦ ៨២៧ ២៨០លានរៀល
- ចំណាយមូលធន...................................................៨ ៩៣៧ ៧៤៨លានរៀល

  ក- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

  ..............................................................២ ៧០៨ ០៣២លានរៀល

  ...ដោយថវិកាថ្នាក់ជាតិ..............................២ ៤៥៨ ០៣២លានរៀល

  ▪ គម្រោងវិនិយោគផ្ទាល់................១ ៨៥៨ ០៣២លានរៀល

▪ បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស

........................................ ៦០០ ០០០លានរៀល

- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ

........................................................ ២៥០ ០០០លានរៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

................................................................៥ ៣២៣ ៧៦៨លានរៀល

គ- ការទូទាត់ការខ្ចី............................................ ៩០៥ ៩៤៨លានរៀល។

**មាត្រា៣ .-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានកំណត់ស្មើនឹង១៦ ៨២៧ ២៨០លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "**ខ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៤ .-**

ចំនួនទឹកប្រាក់នៃឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការគ្រប់គ្រងពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ ត្រូវបានកំណត់ស្មើនឹង២៤ ១៧៧ ០៣៦លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗតាមគម្រោងនិងតាមឆ្នាំ ដូចមានចែងក្នុងតារាង "**គ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៥ .-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានកំណត់ដូចខាងក្រោម ៖

• ឥណទានភ្ជាប់សន្យា................................ ៨ ៩៣៧ ៧៤៨លានរៀល

• ឥណទានទូទាត់.................................. ៨ ៩៣៧ ៧៤៨លានរៀល។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ឥណទាននេះត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា................................ ២ ៧០៨ ០៣២លានរៀល
- ឥណទានទូទាត់...................................... ២ ៧០៨ ០៣២លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា................................ ៥ ៣២៣ ៧៦៨លានរៀល
- ឥណទានទូទាត់...................................... ៥ ៣២៣ ៧៦៨លានរៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា...................................... ៩០៥ ៩៤៨លានរៀល
- ឥណទានទូទាត់.......................................... ៩០៥ ៩៤៨លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗដូចមានចែងក្នុងតារាង "**គ២**" និង"**ឃ**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៦** .-

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលបានរៀបចំនៅក្នុងតារាង "**ក១**" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "**ខ១**" ស្តីពីចំណាយថវិកាថ្នាក់ជាតិត្រូវបានបង្ហាញនៅក្នុងតារាងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិដូចខាងក្រោម ៖

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | តុល្យភាព/ ហិរញ្ញប្បទាន |
|---|---|---|
| I. ចំណូលក្នុងប្រទេសសរុប | ១៩ ៧៨៦ ២៦០ | |
| ១. ចំណូលចរន្ត | ១៩ ៥៩៣ ១១១ | |
| ២. ចំណូលមូលធនក្នុងប្រទេស | ១៩៣ ១៤៩ | |
| II. ចំណាយថវិកាសរុប | ២៤ ៨៥៩ ០៨០ | |
| ១. ចំណាយចរន្ត | ១៦ ៨២៧ ២៨០ | |
| ២. ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី) | ៨ ០៣១ ៨០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ២ ៧០៨ ០៣២ | |
| + ដោយថវិកាថ្នាក់ជាតិ | ២ ៤៥៨ ០៣២ | |
| - គម្រោងវិនិយោគផ្ទាល់ | ១ ៨៥៨ ០៣២ | |
| - បដិភាគវិនិយោគ | ៦០០ ០០០ | |
| + ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍ | ២៥០ ០០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៥ ៣២៣ ៧៦៨ | |
| អតិរេកនៃថវិកាចរន្ត (I.១ -II.១ ) | | +២ ៧៦៥ ៨៣១ |
| ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ (I-II ) | | -៥ ០៧២ ៨២០ |
| III. ហិរញ្ញប្បទាននៃឱនភាព | | +៥ ០៧២ ៨២០ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | +៤ ៦៦៧ ៨២០ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | +២៥០ ០០០ |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | +៥ ៣២៣ ៧៦៨ |
| • ការទូទាត់ការខ្ចី | | -៩០៥ ៩៤៨ |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | +៤០៥ ០០០ |
| • បញ្ញើរាជរដ្ឋាភិបាល | | +៤០៥ ០០០ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី២
## ការខ្ចីនិងការធានារបស់រដ្ឋ

**មាត្រា៧ .-**

សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេក្នុងកម្រិត១ ៤០០ ០០០ ០០០SDR(មួយប៊ីលានបួនរយលានអេសដេអ៊េ)។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ។

នៅក្នុងលក្ខខណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះហត្ថលេខាលើការខ្ចី ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តនៃការខ្ចីនិងការធានានេះ ជូនរដ្ឋសភានិងព្រឹទ្ធសភារៀងរាល់ ៦ខែម្តង។

**មាត្រា៨ .-**

មិនអនុញ្ញាតឱ្យក្រសួង ឬស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យា ដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំ ដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុនិងលក្ខខណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ។

# ជំពូកទី៣
## បទប្បញ្ញត្តិស្តីពីពន្ធដារ

**មាត្រា៩ .-**

មាត្រា៥ នៃច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងមាត្រា៧ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានកែសម្រួលដោយមាត្រា៤ថ្មី នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

មាត្រា៥ .- ថ្មី

ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម ៖

១- ចំពោះនីតិបុគ្គល ពន្ធលើប្រាក់ចំណូលត្រូវបានគណនាចេញពីលទ្ធផលគណនេយ្យដែលសម្រេចបានក្នុងឆ្នាំប្រតិទិននីមួយៗ។ ចំពោះសហគ្រាសថ្មីដែលចាប់ផ្តើមប្រកបអាជីវកម្មក្នុងពេលណាមួយនៃឆ្នាំប្រតិទិន លទ្ធផលគណនេយ្យត្រូវគិតចាប់តាំងពីថ្ងៃដែលផ្តើមប្រកបអាជីវកម្មមកទល់នឹងថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំប្រតិទិននោះ។ ប្រសិនបើមានលទ្ធផលគណនេយ្យច្រើនតៗគ្នាក្នុងឆ្នាំប្រតិទិនណាមួយ លទ្ធផលគណនេយ្យទាំងឡាយត្រូវបូកបញ្ចូលគ្នាធ្វើជាមូលដ្ឋានគិតពន្ធលើប្រាក់ចំណូល។ សហគ្រាសដែលត្រូវបានគ្រប់គ្រងដោយនីតិបុគ្គលអនិវាសនជនអាចស្នើសុំអនុវត្តឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន។

២- ចំពោះរូបវន្តបុគ្គល ពន្ធលើប្រាក់ចំណូលត្រូវបានគណនាចេញពីប្រាក់ចំណូលសរុបដែលសម្រេចបានក្នុងឆ្នាំប្រតិទិននីមួយៗ។

មាត្រា៧ .- ថ្មី (មួយ)

ប្រាក់ចំណូលជាប់ពន្ធ គឺជាប្រាក់ចំណូលសុទ្ធដែលសម្រេចបានពីសកម្មភាពអាជីវកម្ម និងសកម្មភាពនានាក្រៅពីអាជីវកម្មរបស់រូបវន្តបុគ្គលឬនីតិបុគ្គល។ ប្រាក់ចំណូលជាប់ពន្ធ រួមបញ្ចូលទាំងចំណេញមូលធន ការប្រាក់ ថ្លៃឈ្នួល សួយសារ ព្រមទាំងប្រាក់ចំណូលពីទ្រព្យហិរញ្ញវត្ថុ ឬទ្រព្យវិនិយោគ រាប់ទាំងអចលនទ្រព្យផង។

ចំពោះនីតិបុគ្គល ប្រាក់ចំណូលជាប់ពន្ធ គឺជាលទ្ធផលដែលកើតចេញពីការធ្វើនិយតកម្មលើលទ្ធផលគណនេយ្យក្នុងឆ្នាំជាប់ពន្ធ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រាទាំងឡាយនៃជំពូកនេះ។

ចំពោះរូបវន្តបុគ្គល ប្រាក់ចំណូលជាប់ពន្ធ គឺជាលទ្ធផលដែលបានមកពីការយកចំនួនសរុបនៃប្រាក់ចំណូលក្នុងឆ្នាំជាប់ពន្ធ កាត់កងនឹងចំណាយនិងទាយជ្ជទាននានាដែលកំណត់ដោយអនុក្រឹត្យ។

វិធាននិងនីតិវិធីនៃការប្រមូលប្រាក់ពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី៤

## និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ
## ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

**មាត្រា១០.-**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ត្រូវបានយល់ព្រមជាគោលការណ៍ដូចខាងក្រោម ៖

១-ផ្តល់ឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ទឹកប្រាក់ចំនួន២៧ ៨៥០ ០០០ ០០០រៀល(ម្ភៃប្រាំពីរប៊ីលានប្រាំបីរយហាសិបលានរៀលគត់) ដើម្បីទូទាត់ជម្រះបុរេប្រទានរបស់រដ្ឋបាលរាជធានីភ្នំពេញចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៤។

២-យល់ព្រមអនុញ្ញាតឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេបន្ថែមចំនួន៥១៤ ០០០ ០០០ SDR(ប្រាំរយដប់បួនលានអេសដេអេ) សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ នឹងត្រូវអនុម័តនូវចំនួនទឹកប្រាក់ជាក់ស្តែងនៃកិច្ចប្រតិបត្តិការចំណាយថវិកា និងការខ្ចីប្រាក់ពីគេបន្ថែមខាងលើនេះ។

# ជំពូកទី៥

## ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា១១.-**

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា៨៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងបទប្បញ្ញត្តិនៃមាត្រា៣៥ និងមាត្រា៥៤ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ចំណូល-ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សរុបចំនួន២ ១៩៩ ៦៣៦លានរៀល ត្រូវបានកំណត់ដូចខាងក្រោមនេះ ៖

**ក.ថវិការបស់រដ្ឋបាលរាជធានី ខេត្ត**

- ចំណូលថវិកាសរុប................................១ ៤៧៦ ៩៤៦លានរៀល

+ចំណូលចរន្តសរុប.................................១ ៣៩៣ ១៣៨លានរៀល

-ចំណូលសារពើពន្ធ...................... ១ ៣៥១ ៦១៦,៧លានរៀល

-ចំណូលមិនមែនសារពើពន្ធ................ ៤១ ៥២១,៣លានរៀល

+ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ......................៨៣ ៨០៨លានរៀល

• ចំណាយថវិកាសរុប................................ ១ ៤៧៦ ៩៤៦លានរៀល

+ចំណាយចរន្ត........................................ ៧៩២ ០១៥,៥លានរៀល

+ចំណាយមូលធន........................................ ៣១៩ ៦៩៩លានរៀល

+អតិរេករាជធានី ខេត្ត..............................៣៦៥ ២៣១,៥លានរៀល។

ចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត តាមមាតិកាថវិកា ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ក២**" និងឥណទានចំណាយបែងចែកទៅតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗនិងទៅតាមប្រភេទចំណាយ ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ខ២**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**ខ.ថវិការបស់រដ្ឋបាលក្រុង ស្រុក**

• ចំណូលថវិកាសរុប..................................... ១៩៨ ៨៩០លានរៀល

+ចំណូលចរន្តសរុប............................................ ៦ ៨៣០លានរៀល

-ចំណូលមិនមែនសារពើពន្ធ........................ ៦ ៨៣០លានរៀល

+ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ.................១៩២ ០៦០លានរៀល។

• ចំណាយថវិកាសរុប.................................... ១៩៨ ៨៩០លានរៀល

+ចំណាយចរន្ត............................................ ១៩៨ ៨៩០លានរៀល

**គ.ថវិការបស់រដ្ឋបាលឃុំ សង្កាត់**

• ចំណូលថវិកាសរុប.....................................៥២៣ ៨០០លានរៀល

+ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិសរុប............ ៥២៣ ៨០០លានរៀល

-ចំណូលសង្កាត់ចំណុះរាជធានី.......... ៣៦ ៨៤៥,៤៣លានរៀល

-ចំណូលសង្កាត់ចំណុះក្រុង................៤០ ៦៣៤,៣៩លានរៀល

-ចំណូលឃុំ..............................៤៤៦ ៣២០,១៨លានរៀល។

• ចំណាយថវិកាសរុប.................................. ៥២៣ ៨០០លានរៀល

+ចំណាយសរុប......................................... ៥២៣ ៨០០លានរៀល

-ចំណាយសង្កាត់ចំណុះរាជធានី..........៣៦ ៨៤៥,៤៣លានរៀល

-ចំណាយសង្កាត់ចំណុះក្រុង...............៤០ ៦៣៤,៣៩លានរៀល

-ចំណាយឃុំ.................................៤៤៦ ៣២០,១៨លានរៀល។

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់នីមួយៗ ក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកាជាជំពូក គណនី និងអនុគណនី ត្រូវធ្វើឡើង តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពី ក្រសួងមហាផ្ទៃ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

មាត្រា១២ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

មាត្រា១៣ .-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ពុធ ៥ កើត ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៨

នស.រកម.១២១៨.០២៧

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ទឹកប្រាក់ | ភាគរយ |
| សរុបរួមចំណូលថវិកាថ្នាក់ជាតិ (I+II) | | | | 22.437.138,0 | 25.360.028,0 | 2.922.890,0 | 13,0% |
| I. សរុបចំណូលឆ្លងកាត់ធនាគារជាតិ (ក+ខ) | | | | 17.890.199,0 | 20.036.260,0 | 2.146.061,0 | 12,0% |
| ក្នុងនោះចំណូលក្នុងប្រទេស | | | | 17.640.199,0 | 19.786.260,0 | 2.146.061,0 | 12,2% |
| ក. សរុបចំណូលចរន្ត (ក្រ១+ក្រ២) | | | | 17.460.006,0 | 19.593.111,0 | 2.133.105,0 | 12,2% |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | | 17.460.006,0 | 19.593.111,0 | 2.133.105,0 | 12,2% |
| ប្រភេទទី១: ចំណូលសារពើពន្ធ | | | | 15.075.562,0 | 16.879.000,0 | 1.803.438,0 | 12,0% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 12.934.062,0 | 14.468.000,0 | 1.533.938,0 | 11,9% |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណូល) | 3.899.300,0 | 4.330.000,0 | 430.700,0 | 11,0% |
| | | 70011 | ពន្ធលើប្រាក់ចំណូល (រូបវន្តបុគ្គល) | 210.000,0 | 210.000,0 | 0,0 | 0,0% |
| | | 70012 | ពន្ធលើប្រាក់ចំណូល (នីតិបុគ្គល) | 2.662.000,0 | 3.250.000,0 | 588.000,0 | 22,1% |
| | | 70013 | ពន្ធលើប្រាក់បៀវត្ស | 724.000,0 | 870.000,0 | 146.000,0 | 20,2% |
| | | 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (រូបវន្តបុគ្គល) | 236.000,0 | 0,0 | -236.000,0 | -100,0% |
| | | 70015 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (នីតិបុគ្គល) | 67.300,0 | 0,0 | -67.300,0 | -100,0% |
| | 7002 | | ពន្ធប្រយោល | 4.962.262,0 | 5.901.500,0 | 939.238,0 | 18,9% |
| | | 70022 | អាករលើតម្លៃបន្ថែម | 1.938.758,0 | 2.370.500,0 | 431.742,0 | 22,3% |
| | | 70025 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 590.000,0 | 851.000,0 | 261.000,0 | 44,2% |
| | | 70026 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 2.150.000,0 | 2.362.000,0 | 212.000,0 | 9,9% |
| | | 70027 | អាករលើតម្លៃបន្ថែម របបនាំចូល (ជាបន្ទុករបស់រដ្ឋ) | 283.504,0 | 318.000,0 | 34.496,0 | 12,2% |
| | 7003 | | អាករពិសេស | 3.974.000,0 | 4.137.000,0 | 163.000,0 | 4,1% |
| | | 70031 | អាករពិសេសលើទំនិញមួយចំនួន | 729.000,0 | 900.000,0 | 171.000,0 | 23,5% |
| | | 70032 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 760.000,0 | 498.000,0 | -262.000,0 | -34,5% |
| | | 70033 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 2.405.000,0 | 2.654.000,0 | 249.000,0 | 10,4% |
| | | 70034 | អាករពិសេសលើសេវាមួយចំនួន | 80.000,0 | 85.000,0 | 5.000,0 | 6,3% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 98.500,0 | 99.500,0 | 1.000,0 | 1,0% |
| | | 70081 | ពន្ធតែមប្រិ៍ | 8.500,0 | 9.500,0 | 1.000,0 | 11,8% |
| | | 70082 | ប្រាក់ទោសទណ្ឌសារពើពន្ធ | 90.000,0 | 90.000,0 | 0,0 | 0,0% |
| 71 | | | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 2.141.500,0 | 2.411.000,0 | 269.500,0 | 12,6% |
| | 7100 | | ពន្ធនិងអាករលើការនាំចូល | 2.095.700,0 | 2.361.000,0 | 265.300,0 | 12,7% |
| | | 71001 | ពន្ធគយពីការនាំចូល | 1.450.000,0 | 1.563.000,0 | 113.000,0 | 7,8% |
| | | 71002 | កម្រៃពីការងារគយ | 83.000,0 | 98.000,0 | 15.000,0 | 18,1% |
| | | 71003 | ពន្ធគយលើផលិតផលគេលសិលា | 220.000,0 | 340.000,0 | 120.000,0 | 54,5% |
| | | 71004 | អាករបន្ថែមលើផលិតផលគេលសិលាសម្រាប់ថែទាំផ្លូវថ្នល់ | 320.000,0 | 342.000,0 | 22.000,0 | 6,9% |
| | | 71005 | ពិន័យពីការលក់ទំនិញបែអូស និងទំនិញគ្មានការទាមទារ | 500,0 | 500,0 | 0,0 | 0,0% |
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | 20.000,0 | 12.000,0 | -8.000,0 | -40,0% |
| | | 71007 | ពន្ធនាំចូល (ជាបន្ទុករបស់រដ្ឋ) | 2.200,0 | 5.500,0 | 3.300,0 | 150,0% |
| | 7101 | | ពន្ធនិងអាករលើការនាំចេញ | 45.800,0 | 50.000,0 | 4.200,0 | 9,2% |
| | | 71011 | ពន្ធលើការនាំចេញឈើ | 10.000,0 | 10.000,0 | 0,0 | 0,0% |
| | | 71012 | អាករលើការនាំចេញកៅស៊ូ | 33.000,0 | 33.000,0 | 0,0 | 0,0% |

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

<u>ឯកតា:លានរៀល</u>

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ទឹកប្រាក់ | ភាគរយ |
| | | 71014 | អាករលើការនាំចេញទំនិញផ្សេងៗ | 2.300,0 | 6.500,0 | 4.200,0 | 182,6% |
| | | 71016 | ពិន័យផ្សេងៗពីការនាំចេញ | 500,0 | 500,0 | 0,0 | 0,0% |
| ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ | | | | 2.384.444,0 | 2.714.111,0 | 329.667,0 | 13,8% |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 104.515,9 | 127.416,5 | 22.900,6 | 21,9% |
| | 7200 | | ផលសម្បទាន | 85.065,9 | 106.166,5 | 21.100,6 | 24,8% |
| | | 72001 | ផលពីនេសាទ | 2.650,0 | 2.650,0 | 0,0 | 0,0% |
| | | 72002 | ផលពីព្រៃឈើ | 17.412,6 | 17.412,6 | 0,0 | 0,0% |
| | | 72003 | សម្បទានប្រេងកាត | 6.787,0 | 6.166,0 | -621,0 | -9,1% |
| | | 72004 | សម្បទានរ៉ែ | 50.358,3 | 71.842,9 | 21.484,6 | 42,7% |
| | | 72005 | សម្បទានដីសេដ្ឋកិច្ច | 6.500,0 | 7.000,0 | 500,0 | 7,7% |
| | | 72006 | ចំណតយានជំនិះ | 8,0 | 0,0 | -8,0 | -100,0% |
| | | 72008 | ផលសម្បទានផ្សេងៗ | 1.350,0 | 1.095,0 | -255,0 | -18,9% |
| | 7201 | | ផលទុនពីសហគ្រាសសាធារណៈ | 19.450,0 | 21.250,0 | 1.800,0 | 9,3% |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ | 19.450,0 | 21.250,0 | 1.800,0 | 9,3% |
| 73 | | | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 2.036.610,3 | 2.295.830,9 | 259.220,6 | 12,7% |
| | 7300 | | ផលទុនតាមវិស័យ | 804.024,4 | 955.976,3 | 151.951,9 | 18,9% |
| | | 73001 | ផលទុនអាកាសចរស៊ីវិល | 134.440,0 | 247.016,0 | 112.576,0 | 83,7% |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | 438.363,7 | 470.464,5 | 32.100,8 | 7,3% |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | 45.562,0 | 47.132,5 | 1.570,5 | 3,4% |
| | | 73005 | ផលទុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 181.503,2 | 187.335,0 | 5.831,8 | 3,2% |
| | | 73006 | ផលទុនពីវិទ្យុ និងទូរទស្សន៍ | 1.226,6 | 1.164,2 | -62,4 | -5,1% |
| | | 73007 | ផលទុននៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | 33,1 | 36,8 | 3,7 | 11,2% |
| | | 73008 | ផលទុនផ្សេងៗទៀត | 2.895,8 | 2.827,3 | -68,5 | -2,4% |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 88.047,9 | 103.667,9 | 15.620,0 | 17,7% |
| | | 73011 | ការលក់សម្ភារបរិក្ខារ សម្ភារខូចខាត សម្ភារសិក្សា | 118,0 | 124,0 | 6,0 | 5,1% |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | 87.588,9 | 103.171,9 | 15.583,0 | 17,8% |
| | | 73013 | ផលបានពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈ | 5,0 | 5,0 | 0,0 | 0,0% |
| | | 73014 | ការលក់ផលិតផលកសិកម្ម | 270,0 | 262,0 | -8,0 | -3,0% |
| | | 73015 | ការលក់មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រចាស់ៗ ឬ ខូច | 23,0 | 23,0 | 0,0 | 0,0% |
| | | 73016 | ការលក់ឧបករណ៍អេឡិចត្រូនិចចាស់ៗ ឬ ខូច | 3,0 | 3,0 | 0,0 | 0,0% |
| | | 73017 | ការលក់ឧបករណ៍អគ្គិសនីចាស់ៗ ឬ ខូច | 2,0 | 2,0 | 0,0 | 0,0% |
| | | [illegible] | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ ផ្សេងៗទៀត | 38,0 | 77,0 | 39,0 | 102,6% |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល (1) | 29.385,5 | 32.889,5 | 3.504,0 | 11,9% |
| | | 73023 | ផលពីការបង្កើតសហគ្រាស | 21.478,4 | 24.635,3 | 3.156,9 | 14,7% |
| | | 73024 | ផលពីការប្រឡងសិទ្ធិប្រឡង | 2.437,5 | 2.075,5 | -362,0 | -14,9% |
| | | 73026 | ចំណូលពីថ្រូដាប់ក្តី | 3.903,0 | 4.248,4 | 345,4 | 8,8% |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 1.566,6 | 1.930,3 | 363,7 | 23,2% |
| | 7304 | | ផលពីសេវាកម្ម | 65.925,0 | 75.095,0 | 9.170,0 | 13,9% |
| | | 73042 | កម្រៃនៃការថែទាំ | 9.270,8 | 10.870,4 | 1.599,6 | 17,3% |

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៨ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៩ | ប្រៀបធៀប ទឹកប្រាក់ | ប្រៀបធៀប ភាគរយ |
|---|---|---|---|---|---|---|---|
| | | 73043 | សេវាសុរិយោដី | 36.099,7 | 43.125,0 | 7.025,3 | 19,5% |
| | | 73044 | សេវាសំណង់ | 11.004,4 | 10.284,0 | -720,4 | -6,5% |
| | | 73045 | សេវាផ្តល់ព្រឹត្តិបត្រថ្កោលទោស | 2.376,0 | 2.581,2 | 205,2 | 8,6% |
| | | 73047 | សេវាលើពន្ធប្រថាប់ត្រា | 1.000,0 | 2.000,0 | 1.000,0 | 100,0% |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 6.174,1 | 6.234,4 | 60,3 | 1,0% |
| | 7306 | | កម្រៃប្រតិបត្តិការផ្សេងៗទៀត | 268.332,6 | 322.156,4 | 53.823,8 | 20,1% |
| | | 73061 | ចំណូលពីកាតព្វកិច្ចកាស៊ីណូ | 186.511,0 | 226.511,0 | 40.000,0 | 21,4% |
| | | 73062 | ចំណូលពីកាតព្វកិច្ចឆ្នោត | 1.930,5 | 2.509,7 | 579,2 | 30,0% |
| | | 73065 | ចំណូលពីអាជ្ញាប័ណ្ណនាំចេញ | 30,0 | 50,0 | 20,0 | 66,7% |
| | | 73066 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 36.403,1 | 40.085,7 | 3.682,6 | 10,1% |
| | | 73067 | កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | 43.458,0 | 53.000,0 | 9.542,0 | 22,0% |
| | 7307 | | ការជួលទ្រព្យសម្បត្តិរដ្ឋ | 28.182,1 | 32.692,7 | 4.510,6 | 16,0% |
| | | 73071 | ការជួលដីទំនេរ | 11.122,1 | 16.628,4 | 5.506,3 | 49,5% |
| | | 73072 | ការជួលដីមានអគារ | 13.393,9 | 12.823,9 | -570,0 | -4,3% |
| | | 73073 | ការជួលអគារ ឬ សំណង់ផ្សេងៗ | 3.278,9 | 3.000,0 | -278,9 | -8,5% |
| | | 73074 | ការជួលសម្ភារបរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ | 297,2 | 240,4 | -56,8 | -19,1% |
| | | 73078 | ផលពីការជួលផ្សេងៗ | 90,0 | 0,0 | -90,0 | -100,0% |
| | 7308 | | ផលពីការគ្រប់គ្រងរដ្ឋបាល (2) | 752.712,8 | 773.353,1 | 20.640,3 | 2,7% |
| | | 73081 | ចំណូលពីការផ្តល់លិខិតឆ្លងដែន | 182.499,2 | 181.924,0 | -575,2 | -0,3% |
| | | 73082 | ចំណូលពីការផ្តល់ទិដ្ឋាការ | 428.208,9 | 446.757,0 | 18.548,1 | 4,3% |
| | | 73083 | ចំណូលពីការលក់លេខចុះបញ្ជីយានយន្ត | 3.500,0 | 4.300,0 | 800,0 | 22,9% |
| | | 73084 | ចំណូលពីការចុះបញ្ជីយានយន្ត និងជលយាន | 7.036,3 | 6.493,8 | -542,5 | -7,7% |
| | | 73085 | ចំណូលពីការផ្តល់ប័ណ្ណបើកបរគ្រប់ប្រភេទ | 9.185,0 | 6.075,4 | -3.109,6 | -33,9% |
| | | 73086 | ផលពីការត្រួតពិនិត្យអនាម័យសត្វ | 5.368,9 | 5.272,8 | -96,1 | -1,8% |
| | | 73087 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | 116.914,5 | 122.530,1 | 5.615,6 | 4,8% |
| 74 | | | ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 36.049,8 | 31.274,3 | -4.775,5 | -13,2% |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 23.837,8 | 22.212,3 | -1.625,5 | -6,8% |
| | | 74011 | ការពិន័យជាប្រាក់លើបទល្មើសចរាចរណ៍ផ្លូវគោក | 14.000,0 | 10.000,0 | -4.000,0 | -28,6% |
| | | 74012 | ការពិន័យ និងការដាក់ទណ្ឌកម្មពិន័យជាប្រាក់ | 9.837,8 | 12.212,3 | 2.374,5 | 24,1% |
| | 7403 | | ចំណូលពីការរឹបអូស | 12.150,0 | 9.000,0 | -3.150,0 | -25,9% |
| | | 74032 | ចំណូលពីការរឹបអូសទ្រព្យសម្បត្តិ | 12.150,0 | 9.000,0 | -3.150,0 | -25,9% |
| | 740[illegible] | | ផលពីការពិន័យផ្សេងៗ | 62,0 | 62,0 | 0,0 | 0,0% |
| | | [illegible] | ផលពីការពិន័យផ្សេងៗ | 62,0 | 62,0 | 0,0 | 0,0% |
| 75 | | | ការឧបត្ថម្ភ និង អំណោយ | 124.733,0 | 132.201,3 | 7.468,3 | 6,0% |
| | 7508 | | ចំណូលពីប្រភពផ្សេងៗ | 124.733,0 | 132.201,3 | 7.468,3 | 6,0% |
| | | [illegible] | ផលពីការរួមចំណែកការពារបរិស្ថាន | 1.853,0 | 2.201,3 | 348,3 | 18,8% |
| | | 75082 | ផលពីការរួមចំណែកការពារព្រៃឈើ | 80,0 | 0,0 | -80,0 | -100,0% |
| | | 75088 | ចំណូលពីប្រភពផ្សេងៗទៀត | 122.800,0 | 130.000,0 | 7.200,0 | 5,9% |
| 76 | | | ផលហិរញ្ញវត្ថុ | 82.526,0 | 127.379,0 | 44.853,0 | 54,4% |

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ទឹកប្រាក់ | ភាគរយ |
| | 7601 | | ការប្រាក់នៃការឱ្យខ្ចីនិងការប្រាក់នៃប្រាក់បញ្ញើ | 82.526,0 | 127.379,0 | 44.853,0 | 54,4% |
| | | 76011 | ការប្រាក់លើការឱ្យខ្ចី | 82.526,0 | 127.379,0 | 44.853,0 | 54,4% |
| 77 | | | ផលផ្សេងៗ និងផលពិសេស | 9,0 | 9,0 | 0,0 | 0,0% |
| | 7704 | | ចំណូលពីការលក់អគារជម្រះបញ្ជីសារពើភណ្ឌ | 3,0 | 3,0 | 0,0 | 0,0% |
| | | 77041 | ចំណូលពីការលក់អគារជម្រះបញ្ជីសារពើភណ្ឌ | 3,0 | 3,0 | 0,0 | 0,0% |
| | 7705 | | ចំណូលពីការលក់រថយន្ត ឧបករណ៍ និងសម្ភារបរិក្ខារ ជាអចលនវត្ថុ | 6,0 | 6,0 | 0,0 | 0,0% |
| | | 77052 | ចំណូលពីការលក់រថយន្ត | 3,0 | 3,0 | 0,0 | 0,0% |
| | | 77054 | ចំណូលពីការលក់ឧបករណ៍ការិយាល័យនិងគ្រឿងសង្ហារឹម | 3,0 | 3,0 | 0,0 | 0,0% |
| ខ.សរុបចំណូលមូលធន ( ក្រុមទី១ + ក្រុមទី២ ) | | | | 430.193,0 | 443.149,0 | 12.956,0 | 3,0% |
| ក្រុមទី១ : ចំណូលពិត ( ប្រភេទទី១ + ប្រភេទទី២ ) | | | | 430.193,0 | 443.149,0 | 12.956,0 | 3,0% |
| ប្រភេទទី១ : ចំណូលពីប្រភពផ្ទាល់ | | | | 180.193,0 | 193.149,0 | 12.956,0 | 7,2% |
| 27 | | | អចលកម្មហិរញ្ញវត្ថុផ្សេងៗ | 180.193,0 | 193.149,0 | 12.956,0 | 7,2% |
| | 2701 | | ការឱ្យខ្ចី ( ការសងវិញនូវមូលធន ) | 180.193,0 | 193.149,0 | 12.956,0 | 7,2% |
| | | 27011 | ការឱ្យខ្ចី ទៅសហគ្រាសសាធារណៈ | 180.193,0 | 193.149,0 | 12.956,0 | 7,2% |
| ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ | | | | 250.000,0 | 250.000,0 | 0,0 | 0,0% |
| 75 | | | ការឧបត្ថម្ភ និង អំណោយ | 125.000,0 | 125.000,0 | 0,0 | 0,0% |
| | 7514 | | ឧបត្ថម្ភធនពីក្រៅប្រទេស សម្រាប់ចំណាយវិនិយោគ | 125.000,0 | 125.000,0 | 0,0 | 0,0% |
| | | 75142 | ឧបត្ថម្ភធនពីក្រៅប្រទេស-ពហុភាគី សម្រាប់ចំណាយវិនិយោគ | 125.000,0 | 125.000,0 | 0,0 | 0,0% |
| 50 | | | ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល | 125.000,0 | 125.000,0 | 0,0 | 0,0% |
| | 5002 | | ការខ្ចីក្រៅប្រទេស | 125.000,0 | 125.000,0 | 0,0 | 0,0% |
| | | 50021 | ការខ្ចីក្រៅប្រទេស-ពហុភាគី | 125.000,0 | 125.000,0 | 0,0 | 0,0% |
| II. សរុបចំណូលអនុវត្តក្រៅតេនាគារជាតិ | | | | 4.546.939,0 | 5.323.768,0 | 776.829,0 | 17,1% |
| ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ | | | | 4.546.939,0 | 5.323.768,0 | 776.829,0 | 17,1% |
| 75 | | | ការឧបត្ថម្ភ និង អំណោយ | 591.102,0 | 1.064.753,0 | 473.651,0 | 80,1% |
| | 7514 | | ឧបត្ថម្ភធនពីក្រៅប្រទេស សម្រាប់ចំណាយវិនិយោគ | 591.102,0 | 1.064.753,0 | 473.651,0 | 80,1% |
| | | 75141 | ឧបត្ថម្ភធនពីក្រៅប្រទេស-ទ្វេភាគី សម្រាប់ចំណាយវិនិយោគ | 295.551,0 | 319.426,0 | 23.875,0 | 8,1% |
| | | 75142 | ឧបត្ថម្ភធនពីក្រៅប្រទេស-ពហុភាគី សម្រាប់ចំណាយវិនិយោគ | 295.551,0 | 745.327,0 | 449.776,0 | 152,2% |
| 50 | | | ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល | 3.955.837,0 | 4.259.015,0 | 303.178,0 | 7,7% |
| | 5002 | | ការខ្ចីក្រៅប្រទេស | 3.955.837,0 | 4.259.015,0 | 303.178,0 | 7,7% |
| | | 50021 | ការខ្ចីក្រៅប្រទេស-ពហុភាគី | 2.373.503,0 | 1.703.606,0 | -669.897,0 | -28,2% |
| | | 50022 | ការខ្ចីក្រៅប្រទេស-ទ្វេភាគី | 1.582.334,0 | 2.555.409,0 | 973.075,0 | 61,5% |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ក២"

## ចំណូលថវិការាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ទឹកប្រាក់ | ភាគរយ |
| | | | **សរុបរួមចំណូលថវិកាថ្នាក់ជាតិ (I+II)** | 1.090.233,0 | 1.476.946,0 | 386.713,0 | 35,5% |
| | | | **I. សរុបចំណូលឆ្លងកាត់តេនាគារជាតិ (ក+ខ)** | 1.090.233,0 | 1.476.946,0 | 386.713,0 | 35,5% |
| | | | **ក្នុងនោះចំណូលក្នុងប្រទេស** | 1.090.233,0 | 1.476.946,0 | 386.713,0 | 35,5% |
| | | | **ក. សរុបចំណូលចរន្ត (ក្រ១+ក្រ២)** | 1.090.233,0 | 1.476.946,0 | 386.713,0 | 35,5% |
| | | | **ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២)** | 1.090.233,0 | 1.476.946,0 | 386.713,0 | 35,5% |
| | | | **ប្រភេទទី១: ចំណូលសារពើពន្ធ** | 910.443,0 | 1.351.616,7 | 441.173,7 | 48,5% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 910.443,0 | 1.351.616,7 | 441.173,7 | 48,5% |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណូល) | 0,0 | 324.237,0 | 324.237,0 | |
| | | 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (រូបវន្តបុគ្គល) | | 251.440,0 | 251.440,0 | |
| | | 70015 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (នីតិបុគ្គល) | | 72.797,0 | 72.797,0 | |
| | 7003 | | អាករពិសេស | 167.922,0 | 178.996,2 | 11.074,2 | 6,6% |
| | | 70035 | អាករសម្រាប់បំភ្លឺសាធារណៈ | 167.922,0 | 178.996,2 | 11.074,2 | 6,6% |
| | 7004 | | អាករលើសេវាដែលបានកំណត់ | 19.218,0 | 21.766,7 | 2.548,7 | 13,3% |
| | | 70045 | អាករលើការស្នាក់នៅ | 19.218,0 | 21.766,7 | 2.548,7 | 13,3% |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬ ការអនុវត្តសកម្មភាព | 250.913,0 | 283.675,0 | 32.762,0 | 13,1% |
| | | 70053 | ពន្ធប៉ាតង់ | 46.541,0 | 58.175,0 | 11.634,0 | 25,0% |
| | | 70054 | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ | 204.372,0 | 225.500,0 | 21.128,0 | 10,3% |
| | 7006 | | ពន្ធប្រថាប់ត្រា | 367.998,0 | 431.824,3 | 63.826,3 | 17,3% |
| | | 70061 | ពន្ធប្រថាប់ត្រា លើតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ | 349.029,0 | 412.248,2 | 63.219,2 | 18,1% |
| | | 70062 | ពន្ធប្រថាប់ត្រា លើតម្លៃមធ្យោបាយដឹកជញ្ជូន ឬ យានយន្តចំពោះការផ្ទេរកម្មសិទ្ធិ | 7.415,0 | 7.371,3 | -43,7 | -0,6% |
| | | 70063 | ពន្ធប្រថាប់ត្រា លើតម្លៃភាគហ៊ុនចំពោះការផ្ទេរភាគហ៊ុន | 740,0 | 921,5 | 181,5 | 24,5% |
| | | 70064 | ពន្ធប្រថាប់ត្រា លើតម្លៃកិច្ចសន្យាចំពោះការផ្គត់ផ្គង់ទំនិញ ឬ សេវា | 6.144,0 | 6.088,6 | -55,4 | -0,9% |
| | | 70065 | ពន្ធប្រថាប់ត្រា លើលិខិតមានលក្ខណៈគតិយុត្ត | 4.670,0 | 5.194,7 | 524,7 | 11,2% |
| | 7007 | | ពន្ធលើអចលនទ្រព្យ | 104.392,0 | 111.117,5 | 6.725,5 | 6,4% |
| | | 70071 | ពន្ធលើអចលនទ្រព្យ (រូបវន្តបុគ្គល) | 93.032,0 | 96.784,0 | 3.752,0 | 4,0% |
| | | 70072 | ពន្ធលើអចលនទ្រព្យ (នីតិបុគ្គល) | 6.940,0 | 8.325,0 | 1.385,0 | 20,0% |
| | | 70073 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | 4.420,0 | 6.008,5 | 1.588,5 | 35,9% |
| | | | **ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ** | 179.790,0 | 125.329,3 | -54.460,7 | -30,3% |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 18.007,4 | 7.967,1 | -10.040,3 | -55,8% |
| | 7200 | | ផលសម្បទាន | 18.007,4 | 7.967,1 | -10.040,3 | -55,8% |
| | | 72004 | សម្បទានរ៉ែ | 5.377,1 | 5.393,4 | 16,3 | 0,3% |
| | | 72006 | ចំណតយានជំនិះ | 1.860,0 | 1.827,9 | -32,1 | -1,7% |
| | | 72007 | ចំណតជលយាន | 261,8 | 372,3 | 110,5 | 42,2% |
| | | 72008 | ផលសម្បទានផ្សេងៗ | 10.508,5 | 373,5 | -10.135,0 | -96,4% |
| 73 | | | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 12.956,6 | 33.554,2 | 20.597,6 | 159,0% |
| | 7300 | | ផលទុនតាមវិស័យ | 18,0 | 10.512,5 | 10.494,5 | 58302,8% |
| | | 72008 | ផលទុនផ្សេងៗទៀត | 18,0 | 10.512,5 | 10.494,5 | 58302,8% |

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ក២"

## ចំណូលថវិការាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ទឹកប្រាក់ | ភាគរយ |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 10,0 | 0,0 | -10,0 | -100,0% |
| | | 73011 | ការលក់សម្ភារបរិក្ខារ សម្ភារខូចខាត សម្ភារសិក្សា | 10,0 | | -10,0 | -100,0% |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល (1) | 1.982,3 | 5.166,1 | 3.183,8 | 160,6% |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 1.982,3 | 5.166,1 | 3.183,8 | 160,6% |
| | 7304 | | ការផ្តល់សេវាកម្ម | 1.088,0 | 7.788,0 | 6.700,0 | 615,8% |
| | | 73043 | សេវាសុរិយោដី | | 5.722,0 | 5.722,0 | |
| | | 73044 | សេវាសំណង់ | | 773,9 | 773,9 | |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 1.088,0 | 1.292,1 | 204,1 | 18,8% |
| | 7305 | | ផលពីទ្រព្យសម្បត្តិអចល័តផ្សេងទៀត | 8.133,2 | 8.046,8 | -86,4 | -1,1% |
| | | 73051 | ចំណូលពីសត្តឃាតដ្ឋាន | 1.013,9 | 921,0 | -92,9 | -9,2% |
| | | 73052 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ | 1.716,6 | 1.732,6 | 16,0 | 0,9% |
| | | 73053 | ចំណូលពីកំពង់ចម្លង | 948,5 | 1.052,4 | 103,9 | 11,0% |
| | | 73054 | ចំណូលពីឃៀត្រី និងកន្លែងបែងចែកផលិតផល | 322,7 | 119,3 | -203,4 | -63,0% |
| | | 73055 | ចំណូលពីភាស៊ីផ្សារ | 3.618,7 | 3.458,5 | -160,2 | -4,4% |
| | | 73058 | ផលពីទ្រព្យសម្បត្តិអចល័តផ្សេងៗ | 512,8 | 763,0 | 250,2 | 48,8% |
| | 7307 | | ការជួលទ្រព្យសម្បត្តិរដ្ឋ | 59,4 | 59,4 | 0,0 | 0,0% |
| | | 73071 | ការជួលដីទំនេរ | 2,4 | 2,4 | 0,0 | 0,0% |
| | | 73073 | ការជួលអគារ ឬ សំណង់ផ្សេងៗ | 57,0 | 57,0 | 0,0 | 0,0% |
| | 7308 | | ផលពីការគ្រប់គ្រងរដ្ឋបាល (2) | 1.665,7 | 1.981,4 | 315,7 | 19,0% |
| | | 73084 | ចំណូលពីការចុះបញ្ជីយានយន្ត និងជលយាន | | 281,8 | 281,8 | |
| | | 73086 | ផលពីការត្រួតពិនិត្យអនាម័យសត្វ | 1.665,7 | 1.699,6 | 33,9 | 2,0% |
| 74 | | | **ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម** | **12,0** | **0,0** | **-12,0** | **-100,0%** |
| | 7408 | | ផលពីការពិន័យផ្សេងៗ | 12,0 | 0,0 | -12,0 | -100,0% |
| | | 74081 | ផលពីការពិន័យផ្សេងៗ | 12,0 | | -12,0 | -100,0% |
| 75 | | | **ការឧបត្ថម្ភ និង អំណោយ** | **148.814,0** | **83.808,0** | **-65.006,0** | **-43,7%** |
| | 7501 | | ឧបត្ថម្ភធនពីថ្នាក់ជាតិ | 148.814,0 | 83.808,0 | -65.006,0 | -43,7% |
| | | 75011 | ឧបត្ថម្ភធនពីក្រសួង-ស្ថាប័ន | 148.814,0 | 83.808,0 | -65.006,0 | -43,7% |

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ខ១"

## ចំណាយថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ក្រសួង ស្ថាប័ន | សរុបរួមចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុបចំណាយចរន្ត | ប្រភេទទី១ មធ្យោបាយនិងសេវា | ប្រភេទទី២ បន្ទុកហិរញ្ញវត្ថុ | ប្រភេទទី៣ អន្តរាគមន៍សាធារណៈ | ប្រភេទទី៤ ចំណាយផ្សេងៗ | ប្រភេទទី៦ ចំណាយមិនបានគ្រោងទុក | សរុបចំណាយមូលធន | ប្រភេទទី១ ការទូទាត់ការខ្ចី | ប្រភេទទី២ អចលកម្ម |
| សរុបរួមចំណាយ | 25.765.028,0 | 16.827.280,0 | 11.211.182,5 | 525.089,0 | 3.536.653,6 | 485.344,9 | 1.069.010,0 | 8.937.748,0 | 905.948,0 | 8.031.800,0 |
| រដ្ឋបាលកណ្តាល | 16.272.060,7 | 12.658.080,7 | 7.250.082,6 | 525.089,0 | 3.329.857,3 | 484.041,8 | 1.069.010,0 | 3.613.980,0 | 905.948,0 | 2.708.032,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 205.270,7 | 205.270,7 | | | 205.270,7 | | | 0 | | 0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 4.169.199,3 | 4.169.199,3 | 3.961.099,9 | | 206.796,3 | 1.303,1 | | 0 | | 0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 5.323.768,0 | | | | | | | 5.323.768,0 | | 5.323.768,0 |
| ក. វិស័យរដ្ឋបាលទូទៅ | 2.463.541,7 | 2.245.785,0 | 1.368.948,5 | | 394.800,0 | 482.036,5 | | 217.756,7 | | 217.756,7 |
| រដ្ឋបាលកណ្តាល | 2.063.762,0 | 2.047.262,0 | 1.170.542,1 | | 394.800,0 | 481.919,9 | | 16.500,0 | | 16.500,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 8.357,0 | 8.357,0 | | | 8.357,0 | | | 0,0 | | 0,0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 198.523,0 | 198.523,0 | 198.406,4 | | | 116,6 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 201.256,7 | | | | | | | 201.256,7 | | 201.256,7 |
| ០១. ព្រះបរមរាជវាំង | 98.414,0 | 98.414,0 | 78.325,0 | | 19.880,0 | 209,0 | | 0,0 | | 0,0 |
| ០២. រដ្ឋសភា | 183.783,0 | 183.783,0 | 178.365,2 | | 5.302,0 | 115,8 | | 0,0 | | 0,0 |
| ០៣. ព្រឹទ្ធសភា | 87.233,0 | 87.233,0 | 82.153,0 | | 5.000,0 | 80,0 | | 0,0 | | 0,0 |
| ០៤. ក្រុមប្រឹក្សាធម្មនុញ្ញ | 11.523,0 | 11.523,0 | 11.384,0 | | 119,0 | 20,0 | | 0,0 | | 0,0 |
| ០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី | 553.109,0 | 415.409,0 | 127.051,0 | | 288.208,0 | 150,0 | | 137.700,0 | | 137.700,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 8.357,0 | 8.357,0 | | | 8.357,0 | | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 137.700,0 | | | | | | | 137.700,0 | | 137.700,0 |
| ០៥.៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 15.430,0 | 15.430,0 | 15.410,0 | | | 20,0 | | 0,0 | | 0,0 |
| ០៨. ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 42.771,0 | 41.556,0 | 41.489,0 | | 25,0 | 42,0 | | 1.215,0 | | 1.215,0 |
| ១. រដ្ឋបាលកណ្តាល | 24.218,0 | 24.218,0 | 24.173,0 | | 25,0 | 20,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 17.338,0 | 17.338,0 | 17.316,0 | | | 22,0 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 1.215,0 | | | | | | | 1.215,0 | | 1.215,0 |
| ០៩. ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | 148.849,0 | 148.849,0 | 141.826,0 | | 5.748,0 | 1.275,0 | | 0,0 | | 0,0 |
| ១០. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 828.515,0 | 796.115,0 | 281.967,0 | | 34.515,0 | 479.633,0 | | 32.400,0 | | 32.400,0 |
| ១. រដ្ឋបាលកណ្តាល | 768.809,0 | 768.809,0 | 254.694,0 | | 34.515,0 | 479.600,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 27.306,0 | 27.306,0 | 27.273,0 | | | 33,0 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 32.400,0 | | | | | | | 32.400,0 | | 32.400,0 |
| ១៤. ក្រសួងផែនការ | 91.138,0 | 91.138,0 | 91.022,0 | | 60,0 | 56,0 | | 0,0 | | 0,0 |
| ១. រដ្ឋបាលកណ្តាល | 43.721,0 | 43.721,0 | 43.631,0 | | 60,0 | 30,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 47.417,0 | 47.417,0 | 47.391,0 | | | 26,0 | | 0,0 | | 0,0 |
| ២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 207.846,0 | 162.996,0 | 138.095,4 | | 24.847,0 | 53,6 | | 44.850,0 | | 44.850,0 |
| ១. រដ្ឋបាលកណ្តាល | 92.599,0 | 76.099,0 | 51.227,0 | | 24.847,0 | 25,0 | | 16.500,0 | | 16.500,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 86.897,0 | 86.897,0 | 86.868,4 | | | 28,6 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 28.350,0 | | | | | | | 28.350,0 | | 28.350,0 |
| ៣០. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | 79.059,0 | 79.059,0 | 78.874,9 | | 2,0 | 182,1 | | 0,0 | | 0,0 |
| ៣១. អាជ្ញាធរសវនកម្មជាតិ | 14.905,0 | 14.905,0 | 14.873,0 | | 9,0 | 23,0 | | 0,0 | | 0,0 |
| ៣៣. ស្ថាប័នប្រឆាំងអំពើពុករលួយ | 46.536,4 | 45.856,0 | 45.670,0 | | 36,0 | 150,0 | | 680,4 | | 680,4 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 680,4 | | | | | | | 680,4 | | 680,4 |
